គោលជំនឿនៃសេចក្តីបង្រៀន

គោលជំនឿសម្រាប់ប្អូនៗកុមារ

# ការណែនាំឱ្យស្គាល់ពី
# គោលជំនឿខ្លីៗរបស់ វ៉េសមីនស្ទើ

*The Westminster Shorter Catechism*

អ្នកនិពន្ធដើម មិនស្គាល់
កែសម្រួល និង សម្រាយពន្យល់ដោយ
លោកគ្រូគង្វាល ជេ. ជេ. លិម
ដោយមានការរួមចំណែកពីលោកគ្រូគង្វាល ដេវីឌ ហីកស៍

បោះពុម្ពខែធ្នូ ឆ្នាំ២០១០

Copyright © Gratia Dei Sola Media

**Catechism for Young Children**
**An Introduction to The Westminster Shorter Catechism**

Original author unknow.
Edited and enlarged by Ps J.J.Lim;
With helpful contribution by Ps David Higgs

© 2013 by Pilgrim Covenant Church

Khmer Language version © Gratia Dei Sola Media

Published by Gratia Dei Sola Media
Blk 203B, Henderson Road, #07 -07, Singaproe 159546.

Website: www.gdsmedia.org
Email:gdsmedia.sg@gmail.com

All rights reserved
Printed in Singapore

Copyright © Gratia Dei Sola Media

# អារម្ភកថា

មូលដ្ឋាននៃការណែនាំពីគោលជំនឿ ត្រូវបានរកឃើញនៅក្នុងសេចក្ដីបង្គាប់របស់លោកសាវ័កប៉ុល ចំពោះលោកធីម៉ូថេ គឺឱ្យលោកធីម៉ូថេ "នឹកចាំ(ទាំងក្នុងសេចក្ដីជំនឿ និងសេចក្ដីស្រឡាញ់ក្នុងអង្គព្រះគ្រីស្ទយេស៊ូវ) ពីអស់ទាំងពាក្យត្រឹមត្រូវ" ដែលធីម៉ូថេ បានឮពីគាត់ (២ធីម៉ូថេ ១:១៣)។

ដើម្បីសម្រួលដល់ការណែនាំពីគោលជំនឿ ដល់កូនចៅរបស់យើងទាំងអស់គ្នា ក្នុងពួកជំនុំភីលហ្គ្រីមខោវីណាន់ (Pilgrim Covenant Church "PCC") យើងខ្ញុំបានរៀបរៀងសៀវភៅមេរៀនមួយឈុត ស្ដីអំពីគោលជំនឿប្រវត្តិព្រះគម្ពីរ និងគោលជំនឿនៃសេចក្ដីបង្រៀន។

គោលជំនឿប្រវត្តិព្រះគម្ពីរបង្រៀនអំពីតំណើរប្រវត្តិសាស្រ្តនៃកាប្រោសលោះតាមរយៈបទគម្ពីរ រីឯគោលជំនឿនៃសេចក្ដីបង្រៀនវិញ សង្ខេបអំពីសេចក្ដី បង្រៀនដ៏សំខាន់បំផុតនៅក្នុងបទគម្ពីរ ឱ្យទៅជាការអះអាងអំពីសេចក្ដីជំនឿ។

គោលជំនឿនៃសេចក្ដីបង្រៀនទាំងពីរនេះ ត្រូវបានរៀបរៀងឡើងសម្រាប់ប្រើប្រាស់នៅក្នុងពួកជំនុំ ដើម្បីទូន្មានដល់កូនៗរបស់យើងពោលគឺ គោលជំនឿខ្លីៗរបស់វេសមីនស្ទឺ និងគោលជំនឿសម្រាប់ប្អូនៗកុមារ។ សៀវភៅគោលជំនឿសម្រាប់ប្អូនៗ កុមារត្រូវបានរៀបរៀងឡើង ដើម្បីជាការសង្ខេប និងជាការណែនាំឱ្យស្គាល់ពីគោលជំនឿខ្លីៗ។

Copyright © Gratia Dei Sola Media

យើងយល់ថាមេរៀននេះល្អព្រោះកូនៗរបស់យើង ដែលមិនទាន់អាចយល់អំពីភាពស្មុគស្មាញនៃគោលជំនឿខ្លីៗនេះនឹងត្រូវបានបង្រៀនតាមរយៈការសិក្សាជាសង្ខេប ជាជំហានកម្រិតមធ្យម ដែលត្រូវបានរៀបរៀងឡើង សម្រាប់វ័យរបស់ពួកគេ ព្រោះគោលបំណងរបស់យើង គឺឱ្យពួកគេនៅតែមានការចងចាំអំពីគោលជំនឿខ្លីៗនេះ ក្នុងរយៈពេលដ៏វែងនៅថ្ងៃណាមួយ។ ឪពុកម្ដាយដែលយល់ថា កូនៗរបស់ខ្លួនអាចចងចាំនូវគោលជំនឿខ្លីៗនេះ (មុនដែលគេយល់អំពីគោលជំនឿនេះ) បានហើយ អាចនឹងចាប់ផ្ដើមបង្ហាត់ពួកគេឱ្យទន្ទេញ គោលជំនឿសង្ខេបខ្លីនេះៗដោយប្រើគោលជំនឿសង្ខេប ធ្វើជាសេចក្ដីអត្ថាធិប្បាយ។

ខ្ញុំចង់បញ្ជាក់ឱ្យច្បាស់ម្តងទៀតថា ការទូន្មានអំពីសេចក្ដីសន្យារបស់ព្រះ ជាម្ចាស់ដល់កូនៗរបស់យើង គឺជាទំនួលខុសត្រូវដ៏ចម្បងរបស់ឪពុកម្ដាយ (ជាពិសេសគឺឪពុកតែម្តង)។

គ្រូបង្រៀនគោលជំនឿ គ្រាន់តែផ្ដល់អាចមេរៀនសង្ខេបតែប៉ុណ្ណោះ រួចធ្វើការសាកល្បងមើលការចងចាំរបស់ពួកគេអំពីគោលជំនឿ ក្នុងរយៈពេលមួយសប្ដាហ៍មកនេះ។

ដូច្នេះឪពុកគ្រប់ៗរូប ត្រូវបានជម្រុញឱ្យពន្យល់ប្រាប់ពីចម្លើយដល់កូនរបស់ខ្លួនមុនពេលចូលរៀនម្ដងៗ។

សូមឱ្យព្រះវរបិតានៃយើងដែលគង់នៅស្ថានសួគ៌ ប្រទានព្រះពរដល់កូនៗ ដែលព្រះបានប្រទានមកឱ្យយើង តាមរយៈមធ្យោបាយនេះ ដើម្បីឱ្យសេចក្ដីពិតនៃព្រះបន្ទូលរបស់ទ្រង់ត្រូវបានរក្សាទុកនៅក្នុងចិត្តពួកគេ ព្រមទាំងបង្រៀនបន្តដល់កូនចៅ

Copyright © Gratia Dei Sola Media

ជំនាន់ក្រោយៗទៀត និងដើម្បីជាការថ្វាយសិរីរុងរឿងដល់ព្រះនាមរបស់ទ្រង់។

**លោកគ្រូគង្វាល ជេ. ជេ. លិម**

Copyright © Gratia Dei Sola Media

# មេរៀនទី ១
# ព្រះដ៏មានព្រះជន្មរស់ និង ព្រះដ៏ពិត
## វគ្គទី១

១. **តើអ្នកណាបង្កើតប្អូនមក?**
ព្រះជាម្ចាស់។

២. **ហេតុអ្វីបានព្រះជាម្ចាស់បង្កើតប្អូនមក?**
ដើម្បីថ្វាយសិរីរុងរឿងដល់ទ្រង់ និងដើម្បីឱ្យមានអំណរក្នុងព្រះអង្គរហូតអស់កល្បជានិច្ច។

៣. **តើប្អូនត្រូវថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់ដោយរបៀបណា?**
ដោយស្រឡាញ់ព្រះអង្គ និងធ្វើតាមបង្គាប់របស់ទ្រង់។

៤. **ហេតុអ្វីក៏ប្អូនត្រូវថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់?**
ព្រោះព្រះអង្គបានបង្កើតខ្ញុំមក ព្រមទាំងថែរក្សាខ្ញុំផង។

៥. **តើមានព្រះលើសពីមួយមែនទេ?**
មានព្រះពិតតែមួយប៉ុណ្ណោះគឺព្រះដ៏មានព្រះជន្មរស់ និងជាព្រះដ៏ពិត។

៦. **ចុះចំណែករូបព្រះដែលធ្វើពីឈើ និងថ្មវិញ តើជាអ្វី?**
រូបព្រះទាំងនោះ គឺជាព្រះក្លែងក្លាយ។

៧. **តើនៅក្នុងព្រះដ៏មានព្រះជន្ម និងជាព្រះដ៏ពិតមានប៉ុន្មានអង្គ?**
មានបីអង្គ។


Copyright © Gratia Dei Sola Media

**៨. តើមានអង្គអ្វីខ្លះ?**

មានព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណបរិសុទ្ធ។

**៩. តើប្អូនអាចរៀនអំពីសេចក្តីស្រឡាញ់ និងស្តាប់បង្គាប់ព្រះជាម្ចាស់នៅកន្លែងណា?**

ពីក្នុងព្រះគម្ពីរតែមួយគត់។

**១០. តើអ្នកណាខ្លះសរសេរព្រះគម្ពីរ?**

ពួកមនុស្សបរិសុទ្ធដែលបានបណ្តាល ដោយព្រះវិញ្ញាណបរិសុទ្ធ។

**ខគម្ពីរចងចាំ៖** "តែព្រះយេហូវ៉ាទ្រង់ជាព្រះដ៏ពិតវិញ ទ្រង់ជាព្រះដ៏មានព្រះជន្មរស់នៅ ក៏ជាមហាក្សត្រដ៏នៅអស់កល្បជានិច្ច"។
(យេរេមា ១០:១០)



Copyright © Gratia Dei Sola Media

# មេរៀនទី ២
# ព្រះដ៏មានព្រះជន្មរស់ និង ព្រះដ៏ពិត
## វគ្គទី២

**១១. តើព្រះជាម្ចាស់ជាអ្វី?**
ទ្រង់ជាវិញ្ញាណ ទ្រង់ធំអស្ចារ្យណាស់ ទ្រង់គង់នៅអស់ កល្ប ជានិច្ចហើយមិនផ្លាស់ប្តូរទេ ។

**១២. ហេតុអ្វីក៏យើងនិយាយថា ទ្រង់ជាវិញ្ញាណ?**
ពីព្រោះទ្រង់គ្មានរូបកាយដូចមនុស្សយើង។

**១៣. ហេតុអ្វីក៏យើងនិយាយថា ទ្រង់ធំអស្ចារ្យណាស់?**
ព្រោះទ្រង់គ្មានអ្វីអាចកំណត់វិសាលភាពទ្រង់បានឡើយ។

**១៤. ហេតុអ្វីក៏យើងនិយាយថា ទ្រង់គង់នៅអស់កល្បជានិច្ច?**
ពីព្រោះ ទ្រង់គ្មានការចាប់ផ្តើម ក៏គ្មានទីបញ្ចប់ដែរ។

**១៥. ហេតុអ្វីក៏យើងនិយាយថា ទ្រង់មិនផ្លាស់ប្តូរ?**
ពីព្រោះទ្រង់គ្រប់លក្ខណ៍ មិនល្អជាងនេះមិនអាក្រក់ជាង នេះហើយព្រះហឫទ័យទ្រង់ក៏មិនប្រែប្រួលដែរ។

**១៦. តើព្រះជាម្ចាស់គង់នៅឯណា?**
ទ្រង់គង់នៅគ្រប់ទីកន្លែង។


Copyright © Gratia Dei Sola Media

**១៧. តើប្អូនអាចមើលព្រះជាម្ចាស់ឃើញដែរឬទេ?**

ទេ! ខ្ញុំមិនអាចមើលព្រះជាម្ចាស់ឃើញទេ ប៉ុន្តែទ្រង់អាចមើលខ្ញុំឃើញ។

**១៨. តើព្រះជាម្ចាស់ទ្រង់ជ្រាប (ដឹង) គ្រប់ការទាំងអស់មែនទេ?**

ពិតមែនហើយ គ្មានការអ្វីអាចលាក់កំបាំងនឹងព្រះអង្គបានឡើយ។

**១៩. តើព្រះជាម្ចាស់អាចធ្វើគ្រប់ការទាំងអស់បានទេ?**

ពិតជាបាន ទ្រង់អាចសម្រេចគ្រប់ការទាំងអស់ តាមបំណងព្រះទ័យដ៏បរិសុទ្ធរបស់ទ្រង់បាន។

**ខគម្ពីរចងចាំ៖** "ឯព្រះទ្រង់ជាវិញ្ញាណ ហើយអ្នកណាដែលថ្វាយបង្គំទ្រង់នោះត្រូវតែថ្វាយបង្គំទ្រង់ដោយវិញ្ញាណ និងសេចក្តីពិតដែរ"។ (យ៉ូហាន ៤:២៤)។


Copyright © Gratia Dei Sola Media

# មេរៀនទី ៣
# កំណើតផែនដី និង និព្វញ្ញាណ

**២០. តើអ្វីទៅជាការគំនិតសម្រេចរបស់ព្រះជាម្ចាស់?**
នោះគឺជាផែនការរបស់ព្រះជាម្ចាស់ សម្រាប់សកលលោកនេះតាំងតែពីដំបូងម្លេះ។

**២១. តើតាំងពីដំបូងមកម្លេះ គឺរាប់ចាប់ពីពេលណាមក?**
គឺតាំងពីមិនទាន់មានចក្រវាលមកម្ល៉េះ។

**២២. តើព្រះជាម្ចាស់បានធ្វើសម្រេចបំណងព្រះទ័យទ្រង់ដូចម្តេច?**
គឺនៅក្នុងស្នាព្រះហស្តនៃការបង្កើតផែនដី និងក្នុងស្នាព្រះហស្តនៃភាពជាព្រះរបស់ព្រះអង្គ។

**២៣. តើស្នាព្រះហស្តនៃការបង្កើតផែនដីគឺជាអ្វី?**
គឺជាការដែលព្រះបានបង្កើតរបស់សព្វសារពើ ដោយគ្មានបានប្រើអ្វីសោះ ក្នុងរយៈពេលប្រាំមួយថ្ងៃ។

**២៤. តើគ្រប់យ៉ាងដែលព្រះបង្កើតមានសណ្ឋានយ៉ាងណាកាលពីដំបូង?**
គ្រប់យ៉ាងល្អឥតខ្ចោះ។

**២៥. ហេតុអ្វីក៏ព្រះជាម្ចាស់បង្កើតសព្វសារពើយ៉ាងនេះ?**
គឺដើម្បីសិរីរុងរឿងរបស់ទ្រង់ផ្ទាល់។


Copyright © Gratia Dei Sola Media

**២៦. តើស្នាព្រះហស្តក្នុងភាពជាព្រះរបស់ទ្រង់ គឺជាអ្វី?**

គឺការដែលព្រះជាម្ចាស់ ធ្វើឱ្យគ្រប់យ៉ាងកើតមានឡើងនៅក្នុងពិភពលោកនេះ។

**២៧. ហេតុអ្វីបានព្រះជាម្ចាស់ធ្វើឱ្យគ្រប់យ៉ាង កើតមានឡើងតាមវិធីរបស់ព្រះអង្គ?**

គឺដើម្បីសិរីរុងរឿងរបស់ទ្រង់ និងដើម្បីការល្អរបស់មនុស្សដែលព្រះអង្គជ្រើសរើស។

**២៨. តើអ្នកណាខ្លះជាមនុស្សដែលព្រះជ្រើសរើស?**

ពួកគេគឺជាមនុស្សដែលព្រះជាម្ចាស់សព្វព្រះទ័យតាំងតែពីអស់កល្បជានិច្ចមកម្ល៉េះ។

**ខគម្ពីរចងចាំៈ** "ត្បិតអញនេះហើយជាព្រះឥតមានឯណាទៀត ឡើយ អញជាព្រះ ហើយគ្មានអ្នកណាដូចអញសោះគំនិត សម្រេចរបស់អញនឹងស្ថិតស្ថេរនៅ អញនឹងធ្វើតាមបំណងចិត្តអញគ្រប់ប្រការ"។ (អេសាយ៤៦:៩-១០)



Copyright © Gratia Dei Sola Media

# មេរៀនទី ៤
# មនុស្ស និង សម្ព័ន្ធមេត្រីនៃកិច្ចការ

**២៩. តើព្រះជាម្ចាស់បង្កើតមនុស្សយ៉ាងដូចម្ដេច?**

ព្រះអង្គបង្កើតឪពុកម្ដាយដំបូងរបស់យើង តាមរូបអង្គទ្រង់។

**៣០. តើឪពុកម្ដាយដំបូងរបស់យើងជាអ្នកណា?**

គឺ អ័ដាម និង អេវ៉ា។

**៣១. តើព្រះជាម្ចាស់បានបង្កើតឪពុកម្ដាយដំបូងរបស់យើងដោយរបៀបណា?**

ទ្រង់យកធូលីដីមកសូន្យជារូបអ័ដាម រួចបង្កើតអេវ៉ាចេញពីរូបសាច់របស់អ័ដាម ។

**៣២. ក្រៅពីរូបកាយ តើព្រះជាម្ចាស់បានប្រទានអ្វីទៀតដល់អ័ដាម និងអេវ៉ា?**

ទ្រង់បានប្រទានព្រលឹងដែលមិនចេះស្លាប់ដល់ពួកគេ។

**៣៣. តើប្អូនមានព្រលឹងមានរូបកាយដែរឬទេ?**

មែនហើយខ្ញុំក៏មានព្រលឹងដែលមិនចេះស្លាប់ដែរ។

**៣៤. តើប្អូនដឹងថា ប្អូនមានព្រលឹងដោយរបៀបណា?**

ព្រះគម្ពីរបានប្រាប់ខ្ញុំដូច្នេះ។

**៣៥. តើព្រះបានបង្កើតអ័ដាមនិងអេវ៉ាក្នុងស្ថានភាពយ៉ាងណា?**

ទ្រង់បង្កើតពួកគាត់មកយ៉ាងបរិសុទ្ធ និងរីករាយ។



Copyright © Gratia Dei Sola Media

**៣៦. តើសម្ព័ន្ធមេត្រី គឺជាអ្វី?**
គឺជាចំណងមិត្តភាព ដែលត្រូវបានចងដោយសម្បថរវាងបុគ្គលពីរនាក់ ឬច្រើននាក់។

**៣៧. តើព្រះជាម្ចាស់ចងសម្ព័ន្ធមេត្រីអ្វីជាមួយនឹងអ័ដាម?**
សម្ព័ន្ធមេត្រីនៃកិច្ចការ។

**៣៨. តើព្រះជាម្ចាស់បានតម្រូវឱ្យអ័ដាមធ្វើអ្វីនៅក្នុងសម្ព័ន្ធមេត្រីនៃកិច្ចការ?**
ឱ្យគាត់ស្តាប់បង្គាប់ទ្រង់គ្មានចន្លោះ។

**៣៩. តើព្រះជាម្ចាស់បានសន្យាអ្វី នៅក្នុងសម្ព័ន្ធមេត្រីនៃកិច្ចការ?**
ទ្រង់បានសន្យានឹងប្រទានជីវិតដល់អ័ដាម បើសិនជាគាត់ស្តាប់បង្គាប់ទ្រង់។

**៤០. តើព្រះជាម្ចាស់ព្រមានអ្វីខ្លះនៅក្នុងសម្ព័ន្ធមេត្រីនៃកិច្ចការ?**
ទ្រង់ព្រមានថានឹងដាក់ទោសឱ្យអ័ដាមស្លាប់ បើសិនជាគាត់មិនស្តាប់បង្គាប់ទ្រង់។

**ខគម្ពីរចងចាំ៖** "ទ្រង់ក៏បង្កើតមនុស្សឱ្យដូចរូបអង្គទ្រង់ គឺបានបង្កើតគេឱ្យចំនឹងរូបអង្គទ្រង់នោះឯង ក៏បង្កើតគេឡើងជាប្រុសជាស្រី"។ (លោកុប្បត្តិ ១:២៧)


Copyright © Gratia Dei Sola Media

# មេរៀនទី ៥
# ការធ្លាក់ចុះរបស់មនុស្ស

**៤១. តើអ័ដាមកាន់តាមសម្ព័ន្ធមេត្រីនៃកិច្ចការដៃរឬទេ?**
ទេ!គាត់បានប្រព្រឹត្តបាបទាស់នឹងព្រះជាម្ចាស់។

**៤២. តើអំពើបាបគឺជាអ្វី?**
អំពើបាបជាសេចក្តីប្រាថ្នាចង់បានរបស់ខ្លួន ឬការល្មើសនឹងក្រឹត្យវិន័យរបស់ព្រះជាម្ចាស់។

**៤៣. តើសេចក្តីប្រាថ្នាចង់បានរបស់ខ្លួនមានន័យយ៉ាងដូចម្តេច?**
សេចក្តីប្រាថ្នាចង់បានរបស់ខ្លួន គឺជាការមិនប្រព្រឹត្តតាមអ្វីដែលព្រះជាម្ចាស់បានបង្គាប់។

**៤៤. តើការល្មើសមានន័យយ៉ាងដូចម្តេច?**
ការប្រព្រឹត្តនូវអ្វីដែលព្រះជាម្ចាស់បានហាមប្រាម។

**៤៥. តើអំពើបាបរបស់ឪពុកម្តាយដំបូងរបស់យើងគឺជាអ្វី?**
គឺការបរិភោគផ្លែឈើដែលព្រះជាម្ចាស់បានហាម។

**៤៦. តើអ្នកណាដែលបានល្បួងពួកគាត់ទាំងពីរនាក់ប្រព្រឹត្តបាប?**
សាតាំងបានល្បួងអេវ៉ា រួចនាងក៏យកផ្លែឈើឱ្យទៅអ័ដាម។

**៤៧. តើមានរឿងអ្វីកើតឡើងចំពោះឪពុកម្តាយដំបូងរបស់យើងនៅពេលដែលគាត់បានប្រព្រឹត្តអំពើបាប?**
ជំនួសឱ្យជីវិតបរិសុទ្ធ និងភាពរីករាយ ពួកគាត់បានក្លាយទៅជាមានបាប និងវេទនាទៅវិញ។


Copyright © Gratia Dei Sola Media

## ៤៨. តើនៅក្នុងសម្ព័ន្ធមេត្រីនៃកិច្ចការអ័ដាមធ្វើអ្វីៗដើម្បីតែខ្លួនឯងមែនទេ?

ទេ! គឺគាត់បានតំណាងឱ្យកូនចៅរបស់គាត់ទាំងអស់។

## ៤៩. តើអ្នកណាខ្លះជាកូនចៅរបស់អ័ដាម?

គ្រប់មនុស្សប្រុសស្រី និងក្មេងៗទាំងអស់សុទ្ធតែជាកូនរបស់អ័ដាមលើកលែងតែព្រះយេស៊ូវគ្រីស្ទ។

## ៥០. តើអំពើបាបរបស់អ័ដាមមានឥទ្ធិពលដូចម្ដេចខ្លះធ្លាក់មកលើមនុស្សជាតិ?

មនុស្សគ្រប់រូបត្រូវកើតមក នៅក្នុងសណ្ឋាននៃអំពើបាបនិងសេចក្ដីវេទនា។

**ខគម្ពីរចងចាំៈ** "អញនឹងធ្វើឱ្យនឹងស្ត្រី គឺទាំងពូជឯង និងពូជនាងមានសេចក្ដីខ្មាំងនឹងគ្នាពូជនាងនឹងកិនក្បាលឯង ហើយឯងនឹងចឹកកែងជើងនាង។ (លោកុប្បត្តិ ៣:១៥)



Copyright © Gratia Dei Sola Media

# មេរៀនទី ៦
# អំពើបាបពីកំណើត

**៥១. តើសភាវៈដ៏ពេញដោយអំពើបាបដែលយើងទទួលពីអ័ដាម មកហៅថាអ្វី?**

គឺជាអំពើបាបពីកំណើត។

**៥២. តើអំពើបាបពីកំណើតកើតចេញអំពីអ្វីខ្លះ?**

ចេញពីកំហុសក្នុងអំពើបាបដំបូងរបស់អ័ដាម និងសណ្ឋានពេញដោយបាប។

**៥៣. តើកំហុសក្នុងអំពើបាបរបស់អ័ដាមមានន័យដូចម្ដេច?**

នោះគឺជាការរស់នៅជាមនុស្សបាប ចំពោះព្រះនេត្ររបស់ព្រះ ព្រោះតែអ័ដាម។

**៥៤. តើការដែលមានសណ្ឋានពេញដោយបាបមានន័យថាម៉េច?**

នោះគឺជាការរស់នៅជាមនុស្សបាបក្នុងចិត្តរបស់ខ្ញុំ ព្រមទាំងការប្រព្រឹត្តបាបរៀងរាល់ថ្ងៃក្នុងទង្វើររបស់ខ្ញុំ។

**៥៥. តើអំពើបាបគ្រប់យ៉ាងសមនឹងទទួលបានអ្វីខ្លះ?**

សេចក្ដីក្រោធ និងបណ្ដាសារពីព្រះជាម្ចាស់។

**៥៦. តើមានអ្នកណាម្នាក់អាចចូលទៅក្នុងស្ថានសួគ៌ ដោយយកសណ្ឋានបាបទៅជាមួយបានដែរទេ?**

ទេ! មិនបានទេ ចិត្តរបស់យើងត្រូវផ្លាស់ប្រែមុនពេលដែលយើងអាចចូលទៅក្នុងស្ថានសួគ៌បាន។



Copyright © Gratia Dei Sola Media

**៥៧. តើការផ្លាស់ប្រែចិត្តត្រូវហៅថាជាអ្វី?**
ការកើតជាថ្មី។

**៥៨. តើអ្នកណាអាចផ្លាស់ប្រែចិត្តរបស់មនុស្សមានបាបបាន?**
គឺមានតែព្រះវិញ្ញាណបរិសុទ្ធតែមួយគត់

**៥៩. តើមាននរណាម្នាក់អាចបានសង្គ្រោះ តាមរយៈសម្ព័ន្ធមេត្រីនៃកិច្ចការដែរឬទេ?**
គ្មាននរណាម្នាក់អាចបានសង្គ្រោះ តាមរយៈសម្ព័ន្ធមេត្រីនៃកិច្ចការឡើយ។

**៦០. ហេតុអ្វីបានជាគ្មាននរណាម្នាក់បានសង្គ្រោះ តាមរយៈសម្ព័ន្ធមេត្រីនៃកិច្ចការ?**
ពីព្រោះ គ្រប់គ្នាសុទ្ធតែកាន់តាមសម្ព័ន្ធមេត្រីនេះមិនបាន ហើយថែមទាំងត្រូវផ្ដន្ទាទោស ដោយសារសម្ព័ន្ធមេត្រីនេះទៀតផង។

**ខគម្ពីរចេងចាំ៖** "ពីដើមអ្នករាល់គ្នាក៏ស្លាប់នៅក្នុងអំពើបាប និងសេចក្ដីស្លាប់ដែរហើយតាមកំណើតរបស់យើង នោះយើងជាមនុស្សជាប់ក្នុងសេចក្ដីខ្ញាល់ ដូចជាមនុស្សដទៃដែរ។ (អេភេសូរ ២:១,៣)


Copyright © Gratia Dei Sola Media

# មេរៀនទី ៧
# សម្ព័ន្ធមេត្រីនៃព្រះគុណ

## វគ្គទី១

**៦១. តើព្រះវរបិតាបង្កើតសម្ព័ន្ធមេត្រីនៃព្រះគុណជាមួយអ្នកណា?**
ជាមួយព្រះគ្រីស្ទ ដែលជាព្រះរាជបុត្រាដ៏អស់កល្បជានិច្ចរបស់ទ្រង់។

**៦២. តើព្រះគ្រីស្ទធ្វើជាតំណាងរបស់អ្នកណា នៅក្នុងសម្ព័ន្ធមេត្រីនៃព្រះគុណ?**
គឺតំណាងឱ្យពួកមនុស្សដែលព្រះអង្គជ្រើសរើស។

**៦៣. តើព្រះគ្រីស្ទបានផ្ដើមធ្វើអ្វីខ្លះ នៅក្នុងម្ព័ន្ធមេត្រីនៃព្រះគុណ?**
រក្សាក្រឹត្យវិន័យទាំងមូលជំនួសរាស្ត្ររបស់ទ្រង់ ព្រមទាំងរងទារុណកម្ម ព្រោះអំពើបាបរបស់ពួកគេផង។

**៦៤. តើព្រះយេស៊ូវគ្រីស្ទនៃយើង ស្គាល់ពីការត្រូវល្បួងឱ្យប្រព្រឹត្តអំពើបាបទេ?**
ពិតជាស្គាល់ ទ្រង់ត្រូវល្បួងក្នុងគ្រប់កិច្ចការទាំងអស់ ដូចជាយើងដែរ។

**៦៥. តើព្រះយេស៊ូវគ្រីស្ទដ៏ជាព្រះទ្រង់ធ្លាប់ប្រព្រឹត្តអំពើបាបតូចមួយដែរឬទេ?**
ទេ! ព្រះអង្គបរិសុទ្ធ ហើយគ្មានទោសសោះ។


Copyright © Gratia Dei Sola Media

## ៦៦. ហេតុអ្វីក៏ព្រះរាជបុត្រានៃព្រះត្រូវវេទនា?

ព្រះគ្រីស្ទដ៏ជាព្រះរាជបុត្រានៃព្រះ បានក្លាយមកជាសាច់ឈាម ដើម្បីឱ្យព្រះអង្គអាចស្ដាប់បង្គាប់ ព្រមទាំងរងទុក្ខវេទនាក្នុងនិស្ស័យជាមនុស្សរបស់យើង ។

## ៦៧. តើជង្វាយលោះ ឬជង្វាយធួនមានន័យយ៉ាងដូចម្ដេច?

គឺភាពយុត្តិធម៌នៃព្រះរបស់ព្រះគ្រីស្ទ តាមរយៈភាពវេទនា និងការសុគតរបស់ទ្រង់ជួសពួកមនុស្សមានបាប។

**ខគម្ពីរចងចាំ៖** "តែលុះវេលាកំណត់បានមកដល់ នោះព្រះទ្រង់បានចាត់ព្រះរាជបុត្រាទ្រង់មកឱ្យចាប់កំណើតនឹងស្ត្រី គឺកើតក្រោមអំណាចនៃក្រឹត្យវិន័យ ដើម្បីនឹងលោះពួកមនុស្សក្រោមក្រឹត្យវិន័យ ប្រយោជន៍ឱ្យយើងបានទទួលសគុណ ទុកជាកូនចិញ្ចឹម"។ (កាឡាទី ៤:៤-៥)


Copyright © Gratia Dei Sola Media

# មេរៀនទី ៨
# សម្ព័ន្ធមេត្រីនៃព្រះគុណ

## វគ្គទី២

**៦៨. តើព្រះវរបិតាចាប់ផ្តើមអ្វីខ្លះនៅក្នុងសម្ព័ន្ធមេត្រីនៃព្រះគុណ?**
គឺផ្តល់ភាពសុចរិត ទទួលចិញ្ចឹមព្រមទាំងញែកពួកអ្នកដែលព្រះគ្រីស្ទត្រូវសុគតជំនួស។

**៦៩. តើការរាប់ជាសុចរិតគឺជាអ្វី?**
គឺជាការអត់ទោសរបស់ព្រះជាម្ចាស់ ចំពោះមនុស្សមានបាប ហើយប្រព្រឹត្តចំពោះគេ ហាក់ដូចជាជាគេមិនមែនជាមនុស្សគ្មានបាបដូច្នេះដែរ។

**៧០. តើការញែកជាបរិសុទ្ធគឺជាអ្វី?**
គឺជាការដែលព្រះជាម្ចាស់ប្រោសមនុស្ស មានបាបអោយមាននូវភាពបរិសុទ្ធនៅក្នុងចិត្ត និងការប្រព្រឹត្ត។

**៧១. តើការទទួលយកមកចិញ្ចឹមមានន័យដូចម្តេច?**
គឺជាការដែលព្រះជាម្ចាស់ ទទួលយើងរាល់គ្នាទៅក្នុងក្រុមគ្រួសាររបស់ទ្រង់ ព្រមទាំងធ្វើឱ្យយើងក្លាយជាកូនព្រះអង្គ។

**៧២. តើព្រះគ្រីស្ទបានស្តាប់បង្គាប់ និងរងទុក្ខសម្រាប់អ្នកណាខ្លះ?**
គឺសម្រាប់អស់អ្នកដែលទ្រង់ជ្រើសរើស គឺអស់អ្នកណាដែលព្រះវរបិតាបានប្រទានដល់ទ្រង់។


Copyright © Gratia Dei Sola Media

## ៧៣. តើព្រះគ្រីស្ទរស់នៅលើផែនដីនេះក្នុងជីវិតបែបណាដែរ?

គឺជីវិតក្រីក្រ និងវេទនា។

## ៧៤. តើព្រះគ្រីស្ទសុគតក្នុងសេចក្តីស្លាប់បែបណាដែរ?

គឺសេចក្តីសុគតដ៏វេទនា និង គួរខ្មាស នៅលើឈើឆ្កាង។

**ខគម្ពីរចងចាំៈ** "ឯខ្ញុំជាអ្នកគង្វាលល្អ ខ្ញុំស្គាល់ចៀមរបស់ខ្ញុំ ហើយចៀមក៏ស្គាល់ខ្ញុំ ដូចជាព្រះវរបិតាទ្រង់ស្គាល់ខ្ញុំ ហើយខ្ញុំក៏ស្គាល់ទ្រង់ដែរ ខ្ញុំប្តូរជីវិតខ្ញុំនឹងចៀម"។ (យ៉ូហាន ១០:១៤-១៥)



Copyright © Gratia Dei Sola Media

# មេរៀនទី ៩
# អំពីការប្រែចិត្ត និង សេចក្តីជំនឿ

**៧៥. តើអ្នកណានឹងបានសង្គ្រោះ?**

មានតែអ្នកដែលព្រះជាម្ចាស់ជ្រើសរើសប៉ុណ្ណោះ។

**៧៦. តើប្អូនដឹងថា ប្អូនគឺជាមនុស្សដែលព្រះជ្រើសរើសបានយ៉ាងដូចម្តេច?**

ខ្ញុំនឹងប្រែចិត្តចេញពីអំពើបាប ជឿលើព្រះគ្រីស្ទ ហើយរស់នៅក្នុងជីវិតដ៏បរិសុទ្ធ។

**៧៧. តើការប្រែចិត្តមានន័យដូចម្តេច?**

គឺការសោកស្តាយចំពោះការប្រព្រឹត្តបាបទាំងស្អប់ ហើយបោះបង់ទង្វើរនោះចោលផង ពីព្រោះការនោះគឺជាការដែលមិនគាប់ព្រះទ័យព្រះជាម្ចាស់។

**៧៨. តើការជឿឬការមិនជំនឿក្នុងព្រះគ្រីស្ទមានន័យយ៉ាងណា?**

មានន័យថា ទុកចិត្តលើព្រះគ្រីស្ទតែមួយគត់ ដើម្បីទទួលបានសេចក្តីសង្គ្រោះ។

**៧៩. តើការទទួលបានសេចក្តីសង្គ្រោះ មានន័យដូចម្តេច?**

មានន័យថា រួចពីអំណាចនៃអំពើបាប ហើយមានជីវិតអស់កល្បជានិច្ច។



Copyright © Gratia Dei Sola Media

**៨០. តើការទទួលបានជីវិតអស់កល្បជានិច្ច មានន័យដូចម្តេច?**
មានន័យថា ស្គាល់និងត្រេកអរតែនឹងព្រះជាម្ចាស់ ក្នុងអង្គព្រះគ្រីស្ទទាំងបច្ចុប្បន្ន និងអស់កល្បជានិច្ច។

**៨១. តើប្អូនអាចប្រែចិត្ត ហើយជឿលើព្រះគ្រីស្ទដោយអំណាចផ្ទាល់ខ្លួនបានដែរទេ?**
ទេ! បើគ្មានជំនួយពីព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះជាម្ចាស់ នោះខ្ញុំមិនអាចធ្វើអ្វីបានសោះ។

**៨២. តើប្អូនៗអាចមានព្រះចេស្ដា នៃព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះជាម្ចាស់យ៉ាងដូចម្តេច?**
ខ្ញុំត្រូវតែអធិស្ឋានទៅព្រះជាម្ចាស់ ដើម្បីទូលសុំព្រះវិញ្ញាណបរិសុទ្ធ។

**៨៣. តើព្រះគ្រីស្ទបានសុគតយូរប៉ុណ្ណាមកហើយ?**
ជាងពីរពាន់ឆ្នាំកន្លងមកហើយ។

**៨៤. តើពួកមនុស្សបរិសុទ្ធត្រូវបានសង្គ្រោះដូចម្តេច មុនពេលការយាងមករបស់ព្រះគ្រីស្ទ?**
ដោយព្រោះតែជំនឿ ជឿលើព្រះអង្គសង្គ្រោះដែលនឹងត្រូវយាងមក។

**៨៥. តើពួកគាត់បានបង្ហាញសេចក្តីជំនឿរបស់ពួកគាត់ដូចម្តេច?**
ដោយការថ្វាយយញ្ញបូជាលើអសនៈរបស់ព្រះជាម្ចាស់។


Copyright © Gratia Dei Sola Media

## ៨៦. តើយញ្ញបូជាទាំងនេះតំណាងឱ្យអ្វីខ្លះ?

តំណាងឱ្យព្រះគ្រីស្ទ ជាកូនចៀមនៃព្រះ ដែលត្រូវសុគតជួសមនុស្សមានបាប។

**ខគម្ពីរចងចាំ៖** "ត្បិតគឺដោយព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះ ដោយសារសេចក្តីជំនឿ ហើយសេចក្តីនោះក៏មិនមែនកើតពីអ្នករាល់គ្នាដែរគឺជាអំណោយទានរបស់ព្រះវិញ ក៏មិនមែនដោយការប្រព្រឹត្តដែរ ក្រែងអ្នកណាអួតខ្លួន"។ (អេភេសូរ២:៨-៩)


Copyright © Gratia Dei Sola Media

# មេរៀនទី ១០
# មុខងារទាំងបីរបស់ព្រះគ្រីស្ទ

**៨៧. តើព្រះគ្រីស្ទមានមុខងារប៉ុន្មានយ៉ាង?**
ព្រះគ្រីស្ទមានមុខងារបីយ៉ាង ។

**៨៨. តើមានអ្វីខ្លះ?**
គឺមុខងារជាហោរា ជាសង្ឃ និងជាស្ដេច។

**៨៩. តើព្រះគ្រីស្ទជាហោរាយ៉ាងដូចម្ដេច?**
ទ្រង់បង្រៀនយើងអំពីព្រះហឫទ័យរបស់ព្រះជាម្ចាស់។

**៩០. តើព្រះគ្រីស្ទជាសង្ឃយ៉ាងដូចម្ដេច?**
ទ្រង់បានសុគតលោះបាបយើងថែមទាំងអង្វរករព្រះជាម្ចាស់ជំនួសពួកយើងទៀតផង។

**៩១. តើព្រះគ្រីស្ទជាស្ដេចយ៉ាងដូចម្ដេច?**
ទ្រង់គ្រប់គ្រងលើយើង ព្រមទាំងការពារយើងរាល់គ្នាផង។

**៩២. ហេតុអ្វីក៏ប្អូនត្រូវការព្រះគ្រីស្ទ ដ៏ជាហោរា?**
ពីព្រោះ ខ្ញុំមិនដឹងអ្វីទាល់តែសោះ។

**៩៣. ហេតុអ្វីក៏ប្អូនត្រូវការព្រះគ្រីស្ទ ដ៏ជាសង្ឃ?**
ពីព្រោះ ខ្ញុំជាមនុស្សមានទោស។

**៩៤. ហេតុអ្វីក៏ប្អូនត្រូវការព្រះគ្រីស្ទ ដ៏ជាស្ដេច?**
ពីព្រោះ ខ្ញុំជាមនុស្សខ្សត់ខ្សោយ ហើយគ្មានទីពឹង។


Copyright © Gratia Dei Sola Media

**ខគម្ពីរចងចាំ៖** "ពីព្រោះមានព្រះតែ១ហើយមានអ្នកសង្រួបសង្រួមតែ១ នៅកណ្តាលព្រះនិងមនុស្ស គឺជាមនុស្សដ៏ជាព្រះគ្រីស្ទយេស៊ូវនោះ"។ (១ធីម៉ូថេ ២:៥)


Copyright © Gratia Dei Sola Media

# មេរៀនទី ១១
# ក្រឹត្យវិន័យទាំងដប់ប្រការ

**៩៥. តើព្រះជាម្ចាស់ប្រទានបញ្ញាត្តិប៉ុន្មានប្រការទៅឱ្យលោកម៉ូសេនៅលើភ្នំស៊ីណាយ?**

បញ្ញាត្តិទាំងដប់ប្រការ។

**៩៦. តើពេលខ្លះបញ្ញាត្តិដប់ប្រការនេះត្រូវគេហៅថាដូចម្ដេច?**

ក្រឹត្យវិន័យរបស់លោកម៉ូសេ។

**៩៧. តើបញ្ញាត្តិបួនប្រការដំបូងបង្រៀនអំពីអ្វីខ្លះ?**

កាតព្វកិច្ចរបស់យើងចំពោះព្រះជាម្ចាស់។

**៩៨. តើបញ្ញាត្តិប្រាំមួយប្រការចុងក្រោយបង្រៀនអំពីអ្វីខ្លះ?**

កាតព្វកិច្ចរបស់យើងចំពោះមនុស្សដូចគ្នា។

**៩៩. តើបញ្ញាត្តិទាំងដប់ប្រការមានន័យដូចម្ដេច?**

ស្រឡាញ់ព្រះម្ចាស់ឱ្យអស់ពីចិត្ត ហើយស្រឡាញ់អ្នកជិតខាងខ្លួនអោយដូចខ្លួនឯងដែរ។

**១០០.តើអ្នកណាជាអ្នកជិតខាងរបស់ប្អូន?**

មនុស្សគ្រប់គ្នា ដែលខ្ញុំអាចបង្ហាញសេចក្ដីសប្បុរសរបស់ខ្ញុំដល់គេគឺជាអ្នកជិតខាងរបស់ខ្ញុំ។



Copyright © Gratia Dei Sola Media

**១០១.តើព្រះជាម្ចាស់សព្វព្រះទ័យអស់អ្នកណាដែលស្រឡាញ់ និងស្តាប់បង្គាប់ទ្រង់មែនទេ?**

ពិតមែនហើយ ទ្រង់មានបន្ទូលថា៖ "អញស្រឡាញ់ដល់អ្នកដែលស្រឡាញ់អញ"។ (សុភាសិត ៨:១៧)

**១០២.តើព្រះមិនសព្វព្រះទ័យនឹងអស់អ្នកដែលមិនស្រឡាញ់ និង មិនស្តាប់បង្គាប់ទ្រង់មែនទេ?**

ពិតមែនហើយ "ព្រះទ្រង់ជាចៅក្រមសុចរិត អើ ទ្រង់ជាព្រះដែលមានសេចក្តីខ្ញាល់ ចំពោះមនុស្សអាក្រក់រាល់តែថ្ងៃ"។ (ទំនុកដម្កើង ៧:១១)

**ខគម្ពីរចងចាំ៖** "នោះព្រះយេស៊ូវឆ្លើយថា ត្រូវឲ្យស្រឡាញ់ព្រះអម្ចាស់ជាព្រះនៃឯងអោយអស់អំពីចិត្ត អស់អំពីព្រលឹង ហើយអស់ពីគំនិតឯង នេះបញ្ញត្តិយ៉ាងសំខាន់ទី១ ហើយបញ្ញត្តិទី២ ក៏បែបដូចគ្នាដែរ គឺថាត្រូវឲ្យស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង"។
(ម៉ាថាយ ២២:៣៧-៣៩)


Copyright © Gratia Dei Sola Media

# មេរៀនទី ១២
# បញ្ញត្តិទី១ - ទី៣

## ១០៣.តើបញ្ញត្តិទី១ និយាយថាដូចម្ដេច?

បញ្ញត្តិទី១ "កុំឱ្យមានព្រះឯណាទៀត នៅចំពោះអញឱ្យសោះ"។

## ១០៤.តើបញ្ញត្តិទី១ បង្រៀនយើងអំពីអ្វីខ្លះ?

ឱ្យយើងថ្វាយបង្គំព្រះជាម្ចាស់តែមួយអង្គគត់។

## ១០៥.តើបញ្ញត្តិទី២ និយាយថាដូចម្ដេច?

បញ្ញត្តិទី២ "កុំឱ្យឆ្លាក់ធ្វើរូបព្រះសម្រាប់ឯងឱ្យសោះ ក៏កុំឱ្យធ្វើរូបណាឱ្យដូចជាអ្វីនៅស្ថានសួគ៌ខាងលើ ឬនៅផែនដីខាងក្រោម ឬនៅក្នុងទឹកដែលទាបជាងដីផង ក៏កុំឱ្យក្រាបសំពះនៅមុខរបស់ទាំងនោះ ឬក៏គោរពប្រតិបត្តិតាមនោះឡើយ។ ត្បិតអញដែលជាព្រះយេហូវ៉ាជាព្រះនៃឯងអញមានសេចក្ដីប្រច័ណ្ឌ ក៏ទម្លាក់ការទុច្ចរិតរបស់ឪពុក ទៅលើកូនចៅរហូតដល់បីហើយបួនដំណាផង ចំពោះអស់អ្នកណាដែលស្អប់អញ តែអញផ្ដល់សេចក្ដីសប្បុរស ដល់ទាំងពាន់ដំណនៃពួកអ្នក ដែលស្រឡាញ់អញ ហើយកាន់តាមបញ្ញត្តិរបស់អញទាំងប៉ុន្មានវិញ។"

## ១០៦.តើបញ្ញត្តិទី២ បង្រៀនអ្វីខ្លះដល់យើង?

គឺឱ្យថ្វាយបង្គំព្រះជាម្ចាស់ តាមវិធីដែលទ្រង់បានកំណត់មកតែប៉ុណ្ណោះបានហើយ។

Copyright © Gratia Dei Sola Media

## ១០៧.តើបញ្ញត្តិទី៣ និយាយថាដូចម្ដេច?

បញ្ញត្តិទី៣ "កុំឱ្យចេញព្រះនាមរបស់ព្រះយេហូវ៉ាជាអាសារឥតការឡើយ ត្បិតព្រះយេហូវ៉ាទ្រង់នឹងមិនរាប់ជាឥតទោសដល់អ្នកណា ដែលចេញព្រះនាមទ្រង់ជាអាសារឥតការនោះទេ"។

## ១០៨.តើបញ្ញត្តិទី៣ បង្រៀនអ្វីខ្លះដល់យើង?

ឱ្យយើងគោរពដល់ព្រះនាម គោរពព្រះបន្ទូល និងគោរពកិច្ចការរបស់ព្រះជាម្ចាស់ ។

**ខគម្ពីរចងចាំ៖** "ឯក្រឹត្យវិន័យរបស់ព្រះយេហូវ៉ានោះគ្រប់លក្ខណ៍ ក៏តែព្រលឹងឡើងវិញ សេចក្តីបន្ទាល់នៃព្រះយេហូវ៉ាជាពិត ក៏ធ្វើឱ្យមនុស្សល្ងង់ខ្លៅមានប្រាជ្ញា"។ (ទំនុកដម្កើង១៩:៧)


Copyright © Gratia Dei Sola Media

# មេរៀនទី ១៣
# បញ្ញត្តិទី៤

**១០៩.តើបញ្ញត្តិទី៤ និយាយថាដូចម្តេច?**

បញ្ញត្តិទី៤ "ចូរឱ្យនឹកចាំពីថ្ងៃឈប់សម្រាក ដើម្បីញែកថ្ងៃនោះចេញជាបរិសុទ្ធ ក្នុងរវាង៦ថ្ងៃនោះត្រូវឱ្យឯង ធ្វើអស់ទាំងការរបស់ឯងចុះ តែឯថ្ងៃទី៧ នោះគឺជាថ្ងៃឈប់សម្រាកថ្វាយព្រះយេហូវ៉ាជាព្រះនៃឯងវិញ នៅថ្ងៃនោះមិនត្រូវធ្វើអ្វីឱ្យសោះ ទោះខ្លួនឯងឬកូនប្រុសស្រីឯងក្តី ទោះបាវប្រុសឬបាវស្រីឯងក្តី ទោះសត្វរបស់ឯង ឬអ្នកដទៃដែលនៅផ្ទះឯងក្តី ត្បិតក្នុង៦ថ្ងៃ ព្រះយេហូវ៉ាទ្រង់បានធ្វើផ្ទៃមេឃផែនដីហើយនឹងសមុទ្រ ព្រមទាំងរបស់ សព្វសារពើក្នុងឋានទាំងនោះដែរ រួចដល់ថ្ងៃទី៧ទ្រង់ឈប់សម្រាក ហេតុនោះបានជាព្រះយេហូវ៉ា ទ្រង់បានប្រទានពរដល់ថ្ងៃឈប់សម្រាកហើយញែកចេញជាបរិសុទ្ធ"។

**១១០.តើបញ្ញត្តិទី៤ បង្រៀនអ្វីខ្លះដល់យើង?**

ឱ្យញែកថ្ងៃសម្រាកចេញជាបរិសុទ្ធ។

**១១១.តើថ្ងៃណាមួយនៃសប្តាហ៍ ជាថ្ងៃសម្រាករបស់គ្រីស្ទបរិស័ទ?**

ថ្ងៃទី១ នៃសប្តាហ៍ត្រូវបានគេហៅថាជាថ្ងៃនៃព្រះអម្ចាស់។

**១១២.ហេតុអ្វីក៏គេហៅថ្ងៃនោះថាជាថ្ងៃនៃព្រះអម្ចាស់?**

ពីព្រោះ ព្រះគ្រីស្ទបានរស់ឡើងវិញពីសុគតនៅថ្ងៃនោះ។



Copyright © Gratia Dei Sola Media

## ១១៣.តើគួរចំណាយពេលក្នុងថ្ងៃសម្រាកយ៉ាងដូចម្ដេច?

គួរចំណាយពេលសម្រាប់អធិស្ឋាន និងសរសើរដម្កើងព្រះក្នុងការស្ដាប់ ការអានព្រះបន្ទូល និងការធ្វើអំពើល្អជាមួយនឹងអ្នកដទៃផង។

**ខគម្ពីរចងចាំៈ**

‶ដូច្នេះ មានសេចក្ដីឈប់សម្រាក ទុកសម្រាប់រាស្ត្ររបស់ព្រះនៅខាងមុខ″។ (ហេព្រើរ ៤:៩)



Copyright © Gratia Dei Sola Media

# មេរៀនទី ១៤
# បញ្ញាត្តិទី៥ - ទី៨

**១១៤.តើបញ្ញាត្តិទី៥ និយាយថាដូចម្ដេច?**

បញ្ញាត្តិទី៥ "ចូរឱ្យគោរពប្រតិបត្តិដល់ឪពុកម្ដាយ ដើម្បីឱ្យបានអាយុវែងនៅក្នុងស្រុក ដែលព្រះយេហូវ៉ាជាព្រះនៃឯងទ្រង់បានប្រទានឱ្យ។

**១១៥.តើបញ្ញាត្តិទី៥ បង្រៀនអ្វីខ្លះដល់យើង?**

ឱ្យស្រឡាញ់ និងស្ដាប់បង្គាប់ឪពុកម្ដាយ ហើយនិងគ្រូបង្រៀនរបស់យើងផង។

**១១៦.តើបញ្ញាត្តិទី៦ និយាយថាដូចម្ដេច?**

បញ្ញាត្តិទី៦ "កុំសម្លាប់មនុស្សឱ្យសោះ"។

**១១៧.តើបញ្ញាត្តិទី៦ បង្រៀនអ្វីខ្លះដល់យើង?**

ឱ្យមានភាពស្ងប់សុខ និងសេចក្ដីស្រឡាញ់ក្នុងគំនិតក្នុងសម្ដីនិងក្នុងការប្រព្រឹត្ត ហើយជៀសវាងពីចេតនាក្រេវក្រោធ។

**១១៨.តើបញ្ញាត្តិទី៧ និយាយថាដូចម្ដេច?**

បញ្ញាត្តិទី៧ "កុំឱ្យផិតគ្នាឱ្យសោះ"។

**១១៩.តើបញ្ញាត្តិទី៧ បង្រៀនអ្វីខ្លះដល់យើង?**

ឱ្យមានភាពបរិសុទ្ធទាំងនៅក្នុងចិត្ត ទាំងពាក្យសម្ដី និងចរិយាប្រព្រឹត្ត។



Copyright © Gratia Dei Sola Media

**១២០.តើបញ្ញត្តិទី៨ និយាយថាដូចម្ដេច?**

បញ្ញត្តិទី៨ "កុំឱ្យលួចប្លន់ឱ្យសោះ" ។

**១២១.តើបញ្ញត្តិទី៨ បង្រៀនអ្វីខ្លះដល់យើង?**

ឱ្យមានចិត្តស្មោះត្រង់ និងខំប្រឹងប្រែងធ្វើការ។

**ខគម្ពីរចងចាំ៖** "ក្មេងរាល់គ្នាអើយ ចូរស្ដាប់បង្គាប់មាតាបិតាខ្លួនក្នុងព្រះអម្ចាស់ ត្បិតធ្វើដូច្នោះទើបបានត្រូវ"។ (អេភេសូរ ៦:១)



Copyright © Gratia Dei Sola Media

# មេរៀនទី ១៥
## បញ្ញាត្តិទី៩ - ទី១០

**១២២.តើបញ្ញាត្តិទី៩ និយាយយ៉ាងដូចម្ដេច?**

បញ្ញាត្តិទី៩ "កុំឱ្យធ្វើជាបន្ទាល់ក្លែងទាស់នឹងអ្នកជិតខាងខ្លួនឱ្យសោះ"។

**១២៣.តើបញ្ញាត្តិទី៩ បង្រៀនអ្វីខ្លះដល់យើង?**

ឱ្យនិយាយសេចក្ដីពិត ហើយកុំនិយាយកុហកឱ្យសោះ។

**១២៤.តើបញ្ញាត្តិទី១០ និយាយថាដូចម្ដេច?**

បញ្ញាត្តិទី១០ "កុំឱ្យលោភចង់បានផ្ទះអ្នកជិតខាងខ្លួនឱ្យសោះ ក៏កុំឱ្យលោភចង់បានប្រពន្ធគេ ឬបាវប្រុសបាវស្រីគេក្ដី ឬគោលា ឬរបស់អ្វីផងអ្នកជិតខាងខ្លួនឱ្យសោះ"។

**១២៥.តើបញ្ញាត្តិទី១០ បង្រៀនអ្វីខ្លះដល់យើង?**

ឱ្យស្កប់ចិត្តនឹងជីវិតរបស់យើង។

**១២៦.តើមាននរណាម្នាក់ អាចកាន់តាមបញ្ញាត្តិដប់ប្រការនេះបានល្អឥតខ្ចោះទេ?**

តាំងតែពីការធ្លាក់ចុះរបស់អ័ដាម គឺគ្មាននរណាម្នាក់អាចធ្វើបានឬកាន់តាមបញ្ញាត្តិទាំងដប់ប្រការនេះឱ្យបាន ឥតខ្ចោះទាល់តែសោះ។



Copyright © Gratia Dei Sola Media

## ១២៧.តើបញ្ញាត្តិដប់ប្រការនេះ មានប្រយោជន៍អ្វីខ្លះចំពោះយើង?

បញ្ញាត្តិនេះបង្រៀនយើងអំពីកាតព្វកិច្ចរបស់ខ្លួន ព្រមទាំងប្រាប់យើងថា យើងត្រូវការព្រះសង្គ្រោះ។

## ១២៨.តើយើងត្រូវកាន់តាមបញ្ញាត្តិដប់ប្រការនេះយ៉ាងដូចម្តេច?

យើងត្រូវកាន់តាមបញ្ញាត្តិទាំងអស់ ដោយសេចក្តីស្រឡាញ់ និងការដឹងគុណដល់ព្រះអម្ចាស់យេស៊ូវ។

**ខគម្ពីរចងចាំ៖** "សេចក្តីនេះចប់តែប៉ុណ្ណោះ ទាំងអស់បានសម្តែងទុក ហើយដូច្នេះចូរកោតខ្លាចដល់ព្រះ ហើយកាន់តាម បញ្ញាត្តិទ្រង់ចុះ ត្បិតប៉ុណ្ណោះឯង ជាកិច្ចទាំងមូលដែលមនុស្សត្រូវធ្វើ"។ (សាស្តា ១២:១៣)



Copyright © Gratia Dei Sola Media

# មេរៀនទី ១៦
# សេចក្ដីអធិស្ឋានរបស់ព្រះអម្ចាស់

**១២៩.តើសេចក្ដីអធិស្ឋានគឺជាអ្វី?**

សេចក្ដីអធិស្ឋាន គឺជាការទូលសុំព្រះជាម្ចាស់ នូវអ្វីដែលទ្រង់សន្យាថានឹងប្រទានឱ្យ។

**១៣០.តើយើងត្រូវអធិស្ឋាននៅដោយនូវឈ្មោះអ្នកណា?**

ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទតែប៉ុណ្ណោះ។

**១៣១.តើព្រះគ្រីស្ទប្រទានអ្វីដល់យើង ដើម្បីនឹងបង្រៀនយើងអំពីរបៀបអធិស្ឋាន?**

សេចក្ដីអធិស្ឋានរបស់ព្រះអម្ចាស់។

**១៣២.ចូរសូត្រសេចក្ដីអធិស្ឋានរបស់ព្រះអម្ចាស់**

ឱព្រះវរបិតានៃយើងខ្ញុំ ដែលគង់នៅស្ថានសួគ៌អើយសូមឱ្យព្រះនាមទ្រង់បានបរិសុទ្ធ សូមឱ្យរាជ្យទ្រង់បានមកដល់។ សូមឱ្យព្រះហឫទ័យទ្រង់ បានសម្រេចនៅផែនដីដូចនៅស្ថានសួគ៌ដែរ។ សូមប្រទានអាហារដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះហើយ សូមអត់ទោស សេចក្ដីកំហុសរបស់យើងខ្ញុំដូចយើងខ្ញុំបានអត់ទោស ដល់អស់អ្នកដែលធ្វើខុសនឹងយើងខ្ញុំដែរ។ សូមកុំនាំយើងខ្ញុំទៅក្នុងសេចក្ដីល្បួងឡើយតែសូមប្រោសយើងខ្ញុំឱ្យរួចពីសេចក្ដីអាក្រក់វិញ ត្បិតរាជ្យព្រះចេស្ដា និងសិរីល្អជារបស់ផងទ្រង់នៅអស់កល្បជានិច្ច។


Copyright © Gratia Dei Sola Media

**១៣៣.តើក្នុងសេចក្តីអធិស្ឋានរបស់ព្រះជាម្ចាស់ មានការទូលសុំប៉ុន្មានដង?**

ប្រាំមួយដង។

**ខគម្ពីរចងចាំ៖** "ចូរសុំនោះតែងនឹងឱ្យមកអ្នក ចូររកនោះតែងនឹងឃើញ ចូរគោះនោះតែងនឹងបើកឱ្យអ្នក"។ (ម៉ាថាយ ៧:៧)



Copyright © Gratia Dei Sola Media

# មេរៀនទី ១៧
# ការទូលសុំលើកទី១ - ទី៣

**១៣៤.តើការទូលសុំលើកទី១ និយាយដូចម្តេច?**

"សូមឱ្យព្រះនាមទ្រង់បានបរិសុទ្ធ" ។

**១៣៥.តើយើងអធិស្ឋានសុំអ្វីខ្លះ នៅក្នុងការទូលសុំលើកទី១?**

សុំឱ្យព្រះនាមទ្រង់ត្រូវបានដម្កើងឡើង តាមរយៈយើងរាល់គ្នានិងមនុស្សគ្រប់គ្នាដែរ។

**១៣៦.តើការទូលសុំលើកទី២ និយាយដូចម្តេច?**

"សូមឱ្យរាជ្យទ្រង់បានមកដល់"។

**១៣៧.តើយើងអធិស្ឋានសុំអ្វីខ្លះ នៅក្នុងការទូលសុំលើកទី២?**

សុំឱ្យដំណឹងល្អត្រូវបានផ្សព្វផ្សាយទៅពេញផែនដី ហើយឱ្យទាំងយើង និងអ្នកដទៃទៀតបានជឿ ហើយស្តាប់តាមដំណឹងល្អនេះ។

**១៣៨.តើការទូលសុំលើកទី៣ និយាយដូចម្តេច?**

"សូមឱ្យព្រះហឫទ័យទ្រង់បានសម្រេចនៅលើផែនដី ដូចនៅស្ថានសួគ៌ដែរ" ។

**១៣៩.តើយើងអធិស្ឋានសុំអ្វីខ្លះ នៅក្នុងការទូលសុំលើកទី៣?**

សុំឱ្យមនុស្សលើផែនដីនេះ បម្រើព្រះអង្គដូចពួកទេវតាបម្រើទ្រង់នៅស្ថានសួគ៌ដែរ។



Copyright © Gratia Dei Sola Media

**ខគម្ពីរចងចាំ៖** "ឱព្រះយេហូវ៉ា ជាព្រះអម្ចាស់នៃយើងខ្ញុំអើយ ព្រះនាមទ្រង់ប្រសើរគ្រប់លើផែនដីយ៉ាងណាទៅ ទ្រង់បានតម្កល់សិរីល្អទ្រង់ទុកនៅលើស្ថានសួគ៌"។ (ទំនុកដម្កើង ៨:១)



Copyright © Gratia Dei Sola Media

# មេរៀនទី១៨
# ការទូលសុំលើកទី៤ - ទី៦

**១៩០.តើការទូលសុំលើកទី៤ គឺជាអ្វី?**

"សូមប្រទានអាហារដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ"។

**១៩១.តើយើងអធិស្ឋានសុំអ្វីខ្លះ នៅក្នុងការទូលសូមលើកទី៤?**

សុំឱ្យព្រះជាម្ចាស់ប្រទាននូវគ្រប់យ៉ាង ដែលចាំបាច់សម្រាប់រូបកាយ និងព្រលឹងរបស់យើង។

**១៩២.តើការទូលសុំលើកទី៥ គឺជាអ្វី?**

"សូមអត់ទោសដល់អ្នកដែលធ្វើខុសនឹងយើងខ្ញុំ ដូចយើងខ្ញុំបានអត់ទោសដល់អ្នកដែលធ្វើខុសនឹងយើងខ្ញុំដែរ"។

**១៩៣.តើយើងអធិស្ឋានសុំអ្វីខ្លះ នៅក្នុងការទូលសុំលើកទី៥?**

សុំឱ្យព្រះជាម្ចាស់អត់ទោសអំពើបាបរបស់យើង ដោយយល់ដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទ ហើយជួយឱ្យយើងអាចអត់ទោសដល់អ្នកដែលធ្វើខុសនឹងយើងដែរ។

**១៩៤.តើការទូលសុំលើកទី៦ គឺជាអ្វី?**

"សូមកុំនាំយើងខ្ញុំទៅក្នុងសេចក្តីល្បួងឡើយ តែសូមប្រោសយើងខ្ញុំឱ្យរួចពីការអាក្រក់វិញ"។

**១៩៥.តើយើងអធិស្ឋានសុំអ្វីខ្លះ នៅក្នុងការទូលសុំលើកទី៦?**

សុំឱ្យព្រះជាម្ចាស់រក្សាយើងឱ្យនៅឆ្ងាយពីអំពើបាប។



Copyright © Gratia Dei Sola Media

**ខគម្ពីរចងចាំ៖** "ចូរស្វែងរកនគរ និងសេចក្ដីសុចរិតនៃព្រះជាមុនសិន ទើបគ្រប់របស់ទាំងអស់ នឹងបានប្រទានមកអ្នករាល់គ្នាថែមទៀតផង"។ (ម៉ាថាយ ៦:៣៣)


Copyright © Gratia Dei Sola Media

# មេរៀនទី ១៩
# មធ្យោបាយនៃព្រះគុណ

**១៤៦.តើយាននៃព្រះគុណគឺជាអ្វី?**

គឺជាមធ្យោបាយដែលព្រះជាម្ចាស់បានកំណត់ ដើម្បីឱ្យយើងអាចលូតលាស់ក្នុងព្រះគ្រីស្ទ។

**១៤៧.តើមធ្យោបាយធម្មតានៃព្រះគុណគឺជាអ្វី?**

ការអាន និងការស្តាប់ព្រះបន្ទូលព្រះជាម្ចាស់ ការប្រោរព្វពិធីអំណោយទានពិសិដ្ឋ និងសេចក្តីអធិស្ឋាន។

**១៤៨.តើពិធីអំណោយទានដ៏ពិសិដ្ឋមានប៉ុន្មាន?**

ពិធីអំណោយទានពិសិដ្ឋមានពីរ ។

**១៤៩.តើមានអ្វីខ្លះ?**

គឺពិធីជ្រមុជទឹកដ៏បរិសុទ្ធ និងពិធីលៀងព្រះអម្ចាស់។

**១៥០.តើអ្នកណាដែលបានតាំងពិធីដ៏ពិសិដ្ឋទាំងនេះឡើង?**

គឺព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

**១៥១.ហេតុអ្វីបានជាព្រះយេស៊ូវគ្រីស្ទតាំងពិធីដ៏ពិសិដ្ឋនេះឡើង?**

ដើម្បីញែកសាវ័កទ្រង់ពីលោកិយ និងដើម្បីកម្សាន្តចិត្តនិងពង្រឹងគេ។



Copyright © Gratia Dei Sola Media

**ខគម្ពីរចងចាំៈ** "ព្រះយេស៊ូវទ្រង់យាងមកមានបន្ទូលនឹងគេថា "គ្រប់ទាំងអំណាចបាន ប្រគល់មកខ្ញុំនៅលើស្ថានសួគ៌ ហើយនៅលើផែនដីផង ដូច្នេះចូរទៅបញ្ចុះបញ្ចូលឱ្យមានសិស្សនៅគ្រប់ទាំងសាសន៍ព្រមទាំងធ្វើបុណ្យជ្រមុជឱ្យដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ ចុះហើយបង្រៀនឱ្យគេ កាន់តាមគ្រប់ទាំងសេចក្ដីដែលខ្ញុំបានបង្គាប់មកអ្នករាល់គ្នាផង ហើយមើល! ខ្ញុំក៏នៅជាមួយនឹងអ្នករាល់គ្នាជារាល់ថ្ងៃដែរដរាបដល់បំផុតកល្ប"។ (ម៉ាថាយ ២៨:១៨-២០) អាម៉ែន!



Copyright © Gratia Dei Sola Media

# មេរៀនទី ២០
# ពិធីជ្រមុជទឹក

**១៥២.តើសញ្ញាអ្វីខ្លះត្រូវបានប្រើនៅក្នុងពិធីជ្រមុជទឹក?**

ការសម្អាតដោយទឹក។

**១៥៣.តើសញ្ញានេះមានន័យថាដូចម្ដេច?**

យើងត្រូវបានសម្អាតពីអំពើបាប ដោយព្រះលោហិតនៃព្រះគ្រីស្ទ។

**១៥៤.តើយើងត្រូវទទួលពិធីជ្រមុជដោយនូវឈ្មោះអ្នកណា?**

ដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ។

**១៥៥.តើអ្នកណាខ្លះ ដែលត្រូវទទួលបុណ្យជ្រមុជទឹក?**

ពួកអ្នកជឿ និងកូនចៅរបស់ពួកគេ។

**១៥៦.ហេតុអ្វីក៏កូនចៅរបស់អ្នកជឿ ត្រូវទទួលពិធីជ្រមុជទឹក?**

ព្រោះការសន្យានៃសម្ព័ន្ធមេត្រី ជាកម្មសិទ្ធរបស់ពួកគេដែរ។

**១៥៧.តើព្រះគ្រីស្ទយកព្រះទ័យទុកដាក់ចំពោះក្មេងៗដែរមែនទេ?**

មែនហើយ ត្បិតទ្រង់មានបន្ទូលថា "ទុកឱ្យកូនក្មេងមកឯខ្ញុំចុះ កុំឃាត់វាឡើយ ត្បិតនគរស្ថានសួគ៌មានសុទ្ធតែមនុស្សដូចវារាល់គ្នា"។

**១៥៨.តើពិធីជ្រមុជទឹករបស់ប្អូនបញ្ជាក់ថាប្អូនជាអ្វី?**

ជាអ្នកដើរតាមព្រះគ្រីស្ទដ៏ពិត។



Copyright © Gratia Dei Sola Media

## ១៥៩.តើពួកក្មេងៗដែលបានទទួលពិធីជ្រមុជទឹកគឺជាគ្រីស្ទបរិស័ទដែរទេ?

ពួកវាក៏ជាគ្រីស្ទបរិស័ទដែរ ប៉ុន្តែមានតែអស់អ្នកណាដែលពិតជាប្រែចិត្ត ហើយជឿលើព្រះគ្រីស្ទប៉ុណ្ណោះ ដែលបានសង្គ្រោះ។

**ខគម្ពីរចងចាំ៖** ‟ត្បិតសេចក្តីសន្យានោះ គឺសន្យាដល់អ្នករាល់គ្នានិងកូនចៅអ្នករាល់គ្នា ព្រមទាំងអស់អ្នកដែលនៅឆ្ងាយដែរ គឺដល់អស់អ្នកណាដែលព្រះអម្ចាស់ ជាព្រះនៃយើងរាល់គ្នាទ្រង់នឹងហៅ៉”។ (កិច្ចការ២:៣៩)


Copyright © Gratia Dei Sola Media

# មេរៀនទី ២១
# ពិធីលៀងព្រះអម្ចាស់

## ១៦០.តើពិធីលៀងព្រះអម្ចាស់គឺជាអ្វី?

គឺជាការបរិភោគនំប៉័ង និងផឹកស្រាទំពាំងបាយជូរ ដើម្បីរំឭកពីការរងទុក្ខ និងការសុគតរបស់ព្រះគ្រីស្ទ។

## ១៦១.តើនំប៉័ងតំណាងឱ្យអ្វី?

ព្រះកាយរបស់ព្រះគ្រីស្ទ ដែលត្រូវកាច់សម្រាប់អំពើបាបរបស់យើង។

## ១៦២.តើស្រាទំពាំងបាយជូរតំណាងឱ្យអ្វី?

ព្រះលោហិតរបស់ព្រះគ្រីស្ទ ដែលត្រូវបង្ហូរសម្រាប់ការសង្គ្រោះរបស់យើង។

## ១៦៣.តើអ្នកណា ទើបមានសិទ្ធិចូលរួមក្នុងពិធីលៀងព្រះអម្ចាស់?

មានតែអស់អ្នកណាដែលប្រែចិត្តចេញពីអំពើបាបរបស់ខ្លួន ជឿ លើព្រះគ្រីស្ទដើម្បីឱ្យបានសេចក្តីសង្គ្រោះ និងអស់អ្នកដែលស្រឡាញ់អ្នកដទៃទៀតប៉ុណ្ណោះ។

## ១៦៤.តើត្រូវទទួលពិធីលៀងព្រះអម្ចាស់ដោយរបៀបណា?

គឺដោយសេចក្តីជំនឿ និងសេចក្តីស្រឡាញ់នៅក្នុងចិត្តចំពោះព្រះ អម្ចាស់យេស៊ូវគ្រីស្ទ។



Copyright © Gratia Dei Sola Media

**១៦៥.តើអ្នកចូលរួមក្នុងពិធីលៀងព្រះអម្ចាស់ដោយសមរម្យនឹងទទួលបានអត្ថប្រយោជន៍អ្វីខ្លះ?**

ការចិញ្ចឹមបំប៉ន និងការលូតលាស់ខាងព្រលឹងវិញ្ញាណនៅក្នុងព្រះគុណ។

**១៦៦.តើអ្នកចូលរួមក្នុងពិធីលៀងព្រះអម្ចាស់ដោយមិនសមរម្យនឹងទទួលបានអ្វីខ្លះ?**

ការជំនុំជម្រះរបស់ព្រះជាម្ចាស់។

**ខគម្ពីរចងចាំ៖** "ត្បិតវេលាណា ដែលអ្នករាល់គ្នាបរិភោគនំបុ័ងនេះ ហើយផឹកពីពែងនេះ នោះឈ្មោះថាសម្តែងសេចក្តីសុគតរបស់ព្រះអម្ចាស់ដរាបដល់ទ្រង់យាងមក"។ (១កូរិនថូស ១១:២៦)



Copyright © Gratia Dei Sola Media

# មេរៀនទី ២២
# កិច្ចការចុងក្រោយ

**១៦៧.បន្ទាប់ពីគេឆ្កាងព្រះគ្រីស្ទ តើទ្រង់ជាប់ក្នុងផ្នូររហូតមែនទេ?**

ទេ!ទ្រង់បានរស់ឡើងវិញនៅថ្ងៃទីបី បន្ទាប់ពីទ្រង់សុគត។

**១៦៨.តើពេលនេះព្រះគ្រីស្ទនៅឯណា?**

នៅឯស្ថានសួគ៌ទាំងទូលអង្គរព្រះវបិតាជំនួសយើង។

**១៦៩.តើទ្រង់នឹងយាងមកវិញមែនទេ?**

ពិតមែនហើយ នៅថ្ងៃចុងក្រោយព្រះគ្រីស្ទនឹងយាងមកជំនុំជម្រះលោកិយទាំងមូល។

**១៧០.តើពេលស្លាប់ទៅ មនុស្សនឹងក្លាយទៅជាអ្វី?**

រូបកាយរបស់គេក្លាយជាធូលីដីវិញ រីឯព្រលឹងរបស់គេទៅឯភពនៃព្រលឹងវិញ្ញាណ។

**១៧១.តើរូបកាយរបស់មនុស្សស្លាប់នឹងត្រូវប្រោសឱ្យមានជីវិតម្តងទៀតទេ?**

ប្រាកដណាស់ "ត្បិតត្រែនឹងឮឡើងមែន នោះពួកមនុស្សស្លាប់គេនឹងរស់ឡើងវិញ"។

**១៧២.តើនឹងអាក្រក់នឹងក្លាយទៅជាយ៉ាងណានៅថ្ងៃជំនុំជម្រះ?**

ពួកគេនឹងត្រូវបោះទៅក្នុងស្ថាននរក។



Copyright © Gratia Dei Sola Media

## ១៧៣.តើស្ថាននរកគឺជាអ្វី?

គឺជាកន្លែងធ្វើទារុណកម្ម និងទណ្ឌកម្មដ៏គួរឱ្យខ្លាចហើយមិនចេះចប់ផង។

## ១៧៤.តើមនុស្សសុចរិតនឹងទៅជាយ៉ាងណា?

ពួកគេនឹងត្រូវនាំយកទៅឯស្ថានសួគ៌។

## ១៧៥.តើស្ថានសួគ៌គឺជាអ្វី?

គឺជាកន្លែងរីករាយ និងពេញដោយសិរីរុងរឿង ជាកន្លែងដែលមនុស្សសុចរិត នៅជាមួយនឹងព្រះជាម្ចាស់អស់កល្បជានិច្ច។

**ខគម្ពីរចងចាំ៖** "តែទាំងអស់គ្នានឹងបានផ្លាស់ប្រែទៅ ក្នុងមួយរំពេចវិញ គឺក្នុងមួយប៉ប្រិចភ្នែកប៉ុណ្ណោះ ក្នុងកាលដែលឮសូរត្រែក្រោយបង្អស់ ត្បិតត្រែនឹងឮឡើងមែន នោះពួកស្លាប់គេនឹងរស់ឡើងវិញ មិនពុករលួយទៀតឡើយ រួចយើងរាល់គ្នានឹងបានផ្លាស់ប្រែទៅ"។
(១កូរិនថូស ១៥:៥២)


Copyright © Gratia Dei Sola Media

# មេរៀនទី ២៣
# ប្រវត្តិនៃការកែទម្រង់ (វគ្គ១)

**១. តើការកែទម្រង់គឺជាអ្វី?**

ការកែទម្រង់គឺជា ការផ្លាស់ប្ដូរគំនិតចេញពីការបង្រៀនដ៏អាក្រក់របស់ពួកជំនុំទីក្រុងរ៉ូម មកឯសេចក្ដីពិតតែមួយគត់នៅក្នុងព្រះគម្ពីរ។

**២. តើចន វីក្លិហ្វ (John Wycliff) ជាអ្នកណា?**

ចន វីក្លិហ្វ ជាមនុស្សម្នាក់ដែលបានបកប្រែគម្ពីរជាភាសាអង់គ្លេស។

**៣. តើចន ហាស (John Huss) គឺជាអ្នកណា?**

ចន ហាស ជាមនុស្សម្នាក់ដែលបានបង្រៀនពីសេចក្ដីពិតដ៏អស្ចារ្យក្នុងគម្ពីរ នៅប្រទេសរបស់គាត់ គឺប្រទេសបូហិមា (Bohemia)។

**៤. តើចូហាន់ ហ្គុធែនប៊ឺក (Johann Gutenberg) គឺជាអ្នកណា?**

ចូហាន់ ហ្គុធែនប៊ឺក គឺជាជនជាតិអាឡឺម៉ង់ម្នាក់ដែលបានបង្កើតម៉ាស៊ីនបោះពុម្ពដែលអាចប្ដូរទីតាំងបាន។

**៥. តើ ម៉ាធីន លូធ័រ (Martin Luther) គឺជាអ្នកណា?**

ម៉ាធីន លូធ័រ គឺជាមនុស្សម្នាក់ដែលបានចាប់ផ្ដើមការកែទម្រង់នៅប្រទេសអាឡឺម៉ង់ ដោយបង្រៀនថាមនុស្សបានសង្គ្រោះដោយសារជំនឿតែម្យ៉ាងគត់។



Copyright © Gratia Dei Sola Media

## ៦. តើអ៊ាល់រិច ហ្សរិងលី (Ulrich Zwingli) គឺជាអ្នកណា?

អ៊ាល់រិច ស្វីងលី ជាមនុស្សម្នាក់ដែលបាននាំយកការកែទម្រង់ទៅកាន់ក្រុងហ្សូរីចប្រទេសស្វីស។

**ខគម្ពីរចងចាំ៖** "ដូច្នេះ ដែលមានស្មរបន្ទាល់មួយហ្វូងធំម្ល៉េះនៅព័ទ្ធជុំវិញយើង នោះត្រូវឱ្យយើងចោលអស់ទាំងបន្ទុក និងអំពើបាបដែលរុំយើងជុំវិញជាងាយម្ល៉េះនោះចេញ ហើយត្រូវរត់មុខទីប្រណាំងដែលនៅមុខយើងដោយអំណត់"។ (ហេព្រើរ ១២:១)



Copyright © Gratia Dei Sola Media

# មេរៀនទី ២៤
# ប្រវត្តិនៃការកែទម្រង់ (វគ្គ២)

## ៧. តើវីលៀម ហ្វារែល (William Farel) ជាអ្នកណា?

លោកគឺជាមនុស្សម្នាក់ ដែលបាននាំយកការកែរទម្រង់ទៅកាន់ទីក្រុងហ្សឺណែវ ប្រទេសស្វីស តាមរយៈការអធិប្បាយដ៏ឆេះឆួលរបស់គាត់។

## ៨. តើ ចន ខាល់វិន (John Calvin) ជាអ្នកណា?

លោកគឺជាគ្រូគង្វាលជនជាតិបារាំង ដែលបានធ្វើឱ្យការកែរទម្រង់ កាន់តែមានភាពល្អប្រសើរ និងកាន់តែរឹងមាំនៅក្នុងសេចក្តីបង្រៀន និងការថ្វាយបង្គំតាមរយៈការបង្រៀនរបស់គាត់។

## ៩. តើចន ណក់ (John Knox) ជាអ្នកណា?

**ចន ណក់** គឺជាព័ន្ធការីជនជាតិស្កុតលែនដែលបានជួយនាំយកការកែទម្រង់ទៅប្រទេសស្កុតលែន និងជាស្ថាបនិកនៃនិកាយប្រេស្ពប៊ីធីរៀន។

## ១០. តើសន្និបាទវែស្ត៍មីនស្ទ័រ (Westminster) គឺជាអ្វី?

សន្និបាទ វែស្ត៍មីនស្ទ័រ គឺជាហ្វូងមនុស្សរបស់ព្រះជាម្ចាស់ ដែលបានជួបប្រជុំគ្នានៅឯព្រះវិហារវែស្ត៍មីនស្ទ័រ ក្នុងទីក្រុងឡុងដ៍ កាលពីជាង៣៦០ឆ្នាំមុន ដើម្បីសរសេរពីការប្រកាសគោលជំនឿព្រមទាំងសំនួរចម្លើយនៃគោលជំនឿដែលយើងកំពុងតែប្រើប្រាស់។


Copyright © Gratia Dei Sola Media

**ខគម្ពីរចងចាំ៖** "ទាំងរំពឹងមើលដល់ព្រះយេស៊ូវដ៏ជាមេផ្ដើម ហើយជាមេសម្រេចសេចក្ដីជំនឿរបស់យើង ដែលទ្រង់បានរងទ្រាំនៅឈើឆ្កាង ទាំងមើលងាយចំពោះសេចក្ដីអាមាស់ខ្មាស់ នោះឱ្យតែបានសេចក្ដីអំណរដែលនៅចំពោះទ្រង់ រួចទ្រង់ក៏គង់ខាងស្តាំបល្ល័ង្កនៃព្រះ"។ (ហេព្រើរ ១២:២)។


Copyright © Gratia Dei Sola Media

# មេរៀនទី ២៥
# ចំណុចទាំង៥ នៃគោលលទ្ធិរបស់កាល់វិន

**១១. តើចំណុចទាំង៥ នៃគោលលទ្ធិរបស់កាល់វិនមានអ្វីខ្លះ?**

ចំណុចទាំង៥នោះសង្ខេបនូវអ្វីដែល ចន ខាល់វិន បានបង្រៀនពីក្នុងព្រះគម្ពីរ ទាក់ទងសេចក្តីសង្គ្រោះរបស់យើងរាល់គ្នា។

**១២. តើចំណុចទី១ នៃគោលលទ្ធិរបស់កាល់វិននិយាយអំពីអ្វី?**

ភាពពុករលួយទាំងស្រុងដែលមានន័យថា មនុស្សមិនអាចសង្គ្រោះខ្លួនឯងបានឡើយ ព្រោះខ្លួនមានអំពើបាបតាំងពីកំណើតទាំងក្នុងការប្រព្រឹត្ត ក្នុងគំនិតនិងក្នុងការនិយាយស្តី។

**១៣. តើចំណុចទី២ នៃគោលលទ្ធិរបស់កាល់វិននិយាយអំពីអ្វី?**

ការជ្រើសរើសដោយឥតល័ក្ខខ័ណ្ឌ ដែលមានន័យថា មនុស្សដែលព្រះជ្រើសរើស អាស្រ័យលើការដែលព្រះសព្វព្រះទ័យ មិនមែនអាស្រ័យលើការល្អដែលមានក្នុងជីវិតរបស់អ្នកនោះឡើយ។

**១៤. តើចំណុចទី៣ នៃគោលលទ្ធិរបស់កាល់វិននិយាយអំពីអ្វី?**

ការប្រោសលោះមានកំណត់ដែលមានន័យថា ព្រះគ្រីស្ទបានរងទុក្ខ ហើយសុគតដើម្បីតែមនុស្សដែលព្រះអង្គជ្រើសរើសប៉ុណ្ណោះ។



Copyright © Gratia Dei Sola Media

## ១៥. តើចំណុចទី៤ នៃគោលលទ្ធិរបស់កាល់វិននិយាយអំពីអ្វី?

ព្រះគុណដែលមិនទទួលមិនបានមានន័យថា មនុស្សដែលព្រះជ្រើសរើសនឹងត្រូវបានសង្គ្រោះជាប្រាកដទេ ព្រោះព្រះវិញ្ញាណបរិសុទ្ធនឹងធ្វើឱ្យមានសេចក្ដីជំនឿនៅក្នុងពួកគេ។

## ១៦. តើចំណុចទី៦ នៃគោលលទ្ធិរបស់កាល់វិននិយាយអំពីអ្វី?

ស្មារតីលះបង់របស់ពួកបរិសុទ្ធ ដែលមានន័យថា គ្រីស្ទបរិស័ទ្ធពិតនឹងមិនដែលឈប់ធ្វើជាគ្រីស្ទបរិស័ទ្ធនោះទេ។

**ខគម្ពីរចងចាំ៖** "ពាក្យនេះគួរជឿ ហើយគួរទទួលគ្រប់យ៉ាងគឺថា ព្រះយេស៊ូវទ្រង់បានយាងមកក្នុងលោកិយ ដើម្បីនឹងជួយសង្គ្រោះមនុស្សមានបាប ដែលខ្ញុំនេះជាលេខមួយក្នុងពួកគេ"។ (១ធីម៉ូថេ ១:១៥)



Copyright © Gratia Dei Sola Media